**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០២៥/០៣/២០១០ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១០

**ជម្រាបមក**

**ឯកឧត្តម យ៉ែម បុញ្ញឫទ្ធិ តំណាងរាស្ត្រមណ្ឌលព្រៃវែង**

**កម្មវត្ថុ** : សំណើបកស្រាយប្រការ ២៦ ៣២ និង ៤៨ ថ្មី ( ពីរ ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

**យោង** : លិខិតរបស់ឯកឧត្តម លេខ ០០០៩/១០ រ.ស ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១០ តាមរយៈ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ចុះលេខ ៣១១ រ.ស ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០១០។

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមមេត្តាជ្រាបថា ក្នុងកិច្ចប្រជុំ នាថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១០ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យសំណើរបស់ឯកឧត្តមរួចហើយ ។ ដោយយោងបទប្បញ្ញត្តិនៃមាត្រា ១៣៦ ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា សំណើបកស្រាយ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ពុំចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

សូមឯកឧត្តម ទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**